**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ...២៥៦១...សខល

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការអនុវត្តវិធានការសុខាភិបាល និងការធ្វើចត្តាឡីស័ក ចំពោះអ្នកដំណើរទាំងអស់ចូលមកប្រទេសកម្ពុជា ចាប់អនុវត្តពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២០ តទៅ

គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា យោងតាមចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ លើលិខិតលេខ ២៥០ សខល ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល ស្តីការអនុវត្តវិធានការសុខាភិបាល និងការធ្វើចត្តាឡីស័ក ចំពោះអ្នកដំណើរទាំងអស់ចូលមកប្រទេសកម្ពុជា ចាប់អនុវត្តពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២០ ដូចខាងក្រោម៖

- ត្រូវធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ ពេញលេញ ចំពោះគ្រប់អ្នកដំណើរទាំងអស់ដែលចូលមកព្រះរាជាណាចក្រកម្ពុជា ក្រោយពីបានធ្វើតេស្តពេលមកដល់កម្ពុជា។ អ្នកដំណើរទាំងអស់ក៏ត្រូវមានវិញ្ញាបនបត្របញ្ជាក់សុខភាព (Health Certificate) ចេញដោយអាជ្ញាធរសុខាភិបាលទទួលស្គាល់ដោយប្រទេសសាមី បញ្ជាក់ថាគ្មានកូវីដ-១៩ មានសុពលភាពរយៈពេល៧២ម៉ោង មុនពេលចេញដំណើរ។
- ផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តយន្តការធានា (Sponsorship Mechanism) ចំពោះអ្នកដំណើរបរទេសជាវិនិយោគិន-ធុរជន បុគ្គលិកក្រុមហ៊ុន អ្នកជំនាញការ និងអ្នកបច្ចេកទេស ដែលទទួលបានការធានា ចូលមកប្រទេសកម្ពុជារយៈពេលតិចជាង ១៤ថ្ងៃ រហូតដល់ស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ មានភាពធូរស្រាល និងទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ជាថ្មីពី **សម្តេចតេជោនាយករដ្ឋមន្ត្រី**។
- បង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ-១៩ បន្ទាប់ពីទទួលបានលទ្ធផលតេស្តកូវីដ-១៩ វិជ្ជមាន ភ្លាម តាមបណ្តាញផ្សព្វផ្សាយផ្លូវការរបស់ក្រសួងសុខាភិបាល ដើម្បីងាយស្រួលក្នុងការស្វែងរកអ្នកពាក់ព័ន្ធ ឲ្យបានឆាប់រហ័ស ដើម្បីបង្កលក្ខណៈឱ្យអ្នកមានការពាក់ព័ន្ធនឹងអ្នកជំងឺកូវីដ-១៩ ចេញមុខទាក់ទងមកក្រសួងសុខាភិបាល ឬអាជ្ញាធរពាក់ព័ន្ធ។
- ក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្តេចតេជោប្រយុទ្ធនឹងជំងឺកូវីដ-១៩ ជួយក្នុងការយកសំណាក និងការងារអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាលសហគមន៍។

ថ្ងៃសុក្រ ៤រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**

**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
-ឯកសារ-កាលប្បវត្តិ